# ធនាគារជាតិ នៃ កម្ពុជា



ធនាគារជាតិនៃកម្ពុជា សាខាខេត្តបន្ទាយមានជ័យ

# របាយការណ៍ ប្រចាំឆ្នាំ
# ២០០៨

## នាយកដ្ឋានត្រួតពិនិត្យ

# អារម្ភកថា



នេះគឺជាការបោះផ្សាយលើកទីបួន នៃរបាយការណ៍ត្រួតពិនិត្យធនាគារប្រចាំឆ្នាំរបស់ធនាគារជាតិនៃកម្ពុជា ។ ក្នុងឆ្នាំ២០០៨ ជាការឆ្លងកាត់នូវដំណាក់កាលដ៏សំខាន់ដែលសេដ្ឋកិច្ចរបស់បណ្តាប្រទេសលើសកលលោកកំពុងតែជួបប្រទះនឹងគ្រោះនៃវិបត្តិហិរញ្ញវត្ថុពិភពលោក ដែលសាយភាយមកពីវិបត្តិឥណទាននិក្ខេបនៅប្រទេសអាមេរិកហើយកម្ពុជាក៏ទទួលស្គាល់ថា សេដ្ឋកិច្ចរបស់ខ្លួនបាននិងកំពុងតែរងផលប៉ះពាល់ពីវិបត្តិហិរញ្ញវត្ថុនេះដែរ តែស្ថិតនៅក្នុងកម្រិតមួយដែលអាចគ្រប់គ្រងបាន ដោយសារប្រទេសកម្ពុជាមានសមាហរណកម្មសេដ្ឋកិច្ចនិងហិរញ្ញវត្ថុនៅក្នុងតំបន់និងនៅលើពិភពលោកកម្រិតទាប ហើយម្យ៉ាងទៀតប្រទេសកម្ពុជាមានអត្ថប្រយោជន៍ជាសក្តានុពលមួយចំនួនដែលអាចការពារ និងឆ្លើយតបទៅនឹងការធ្លាក់ចុះនៃសេដ្ឋកិច្ចនេះ ។

ដើម្បីបញ្ជាក់ឱ្យឃើញពីអត្ថប្រយោជន៍ជាសក្តានុពលនេះ ខ្ញុំសូមលើកយកមកបង្ហាញឱ្យឃើញនូវគំនិតសុទិដ្ឋិនិយមទាំងនេះ ។ ជាការពិតដែលកម្ពុជាបានរងនូវសម្ពាធពីអតិផរណានៅបីត្រីមាសដើមឆ្នាំ ២០០៨ ដោយសារតែការកើនឡើងនូវថ្លៃប្រេងឥន្ធនៈ ថ្លៃនៃទំនិញនៅលើទីផ្សារអន្តរជាតិ ជាពិសេសថ្លៃស្បៀងអាហារ ។ ជាការឆ្លើយតបទៅនឹងសម្ពាធនេះ ក្នុងនាមជាអាជ្ញាធររូបិយវត្ថុ ធនាគារជាតិនៃកម្ពុជាបានចាត់វិធានការជាបន្ទាន់មួយ ដោយអនុវត្តនូវឧបករណ៍នយោបាយរូបិយវត្ថុរបស់ខ្លួនដែលមានស្រាប់ តាមរយៈការបង្កើនអត្រាប្រាក់បម្រុងកាតព្វកិច្ចពីចំនួន ៨% ដល់ទៅ ១៦% ក្នុងគោលបំណងដើម្បីកាត់បន្ថយកំណើនបរិមាណនៃការផ្គត់ផ្គង់រូបិយវត្ថុ តាមរយៈការផ្តល់ឥណទានរបស់ធនាគារ ។ ក្រៅពីនេះធនាគារជាតិនៃកម្ពុជាក៏បានកំណត់ពិដានឥណទានចំនួន ១៥% ចំពោះវិស័យអចលនទ្រព្យ ដែលធ្វើឱ្យសន្ទុះនៃកំណើនឥណទានលើអចលទ្រព្យមានការថយចុះ ហើយធនាគារមានការប្រុងប្រយ័ត្នខ្ពស់ចំពោះការឱ្យខ្ចីលើវិស័យនេះ ។ ទន្ទឹមនឹងនេះដែរ រាជរដ្ឋាភិបាលក៏បានអនុវត្តនូវវិធានការជាកញ្ចប់ផងដែរ ដូចជាការរិតត្បិតការចំណាយសាធារណៈ ការខិតខំប្រមូលពន្ធគយ ការទប់ស្កាត់មួយរយៈនូវការនាំចេញស្រូវ ការលក់ចែកចាយអង្ករក្នុងតម្លៃសមរម្យជាដើម ។ លទ្ធផលដែលទទួលបានសរបញ្ជាក់ឱ្យឃើញថា អតិផរណាមានការថយចុះគួរឱ្យកត់សំគាល់ ពី ១៤% នៅឆ្នាំ ២០០៧ មក ១២.៥% នៅឆ្នាំ២០០៨ ។

ជាមួយនឹងអំណោយផលជាវិជ្ជមានខាងលើ ខ្ញុំសូមបញ្ជាក់បន្ថែមថាប្រព័ន្ធធនាគារនៅកម្ពុជា ជាប្រព័ន្ធធនាគារមានអាជីវកម្មបែបប្រពៃណី ដោយពុំមានសមាហរណកម្មខ្លាំងជាមួយនឹងទីផ្សារហិរញ្ញវត្ថុអន្តរជាតិទេ ហើយដោយឈរលើមូលដ្ឋាននេះ ធនាគារជាតិនៃកម្ពុជាមានសុទិដ្ឋិនិយមថា ប្រព័ន្ធធនាគារនៅកម្ពុជាមិនទទួលរងឥទ្ធិពលនៃវិបត្តិហិរញ្ញវត្ថុពិភពលោកដោយផ្ទាល់ទេ ។ ក៏ប៉ុន្តែធនាគារជាតិនៃកម្ពុជានៅតែខិតខំពង្រឹងការត្រួតពិនិត្យ និងចេញបទបញ្ជាប្រុងប្រយ័ត្ន

នានា ជាពិសេសពាក់ព័ន្ធការត្រួតពិនិត្យផ្អែកលើហានិភ័យ (Risk based supervision) ឱ្យស្របតាមស្តង់ដារអន្តរជាតិ ដើម្បីរក្សាឱ្យបាននូវប្រព័ន្ធធនាគារមានសុវត្ថិភាព និងសុខភាពល្អ ការពារបាននូវហានិភ័យផ្សេងដែលអាចនឹងកើតមានឡើងចំពោះវិស័យនេះ ដោយហេតុថាវិស័យនេះ ជាកត្តាចលករមួយក្នុងការចូលរួមចំណែកការអភិវឌ្ឍសេដ្ឋកិច្ចជាតិ ។

ជាក់ស្តែង នាឆ្នាំ២០០៨ នេះ ជាទូទៅប្រព័ន្ធធនាគាររក្សាបាននូវភាពគ្រប់គ្រាន់នៃដើមទុន ដោយមានអនុបាតសាធនភាពស្ថិតក្នុងកម្រិត ២៨% ដែលធៀបនឹង ឆ្នាំ២០០៧ មានចំនួន ២៤% ខ្ពស់ជាងការតម្រូវដោយបទប្បញ្ញត្តិចំនួន ១៥% ។ សាច់ប្រាក់ងាយស្រួលស្ថិតក្នុងកម្រិត ៨១% ធៀបឆ្នាំ២០០៧ មានចំនួន១០៤% ។ អនុបាតឥណទានមិនដំណើរការបានកើនឡើងពី ៣.៤៤% នៅឆ្នាំ ២០០៧ ទៅ ៣.៦៨% ។ ទ្រព្យសកម្មរបស់ធនាគារមានការកើនឡើងចំនួន ២៦% ធៀបនឹងឆ្នាំ ២០០៧ ។ ឥណទាននិងប្រាក់បញ្ញើមានចំនួន ៩.៨៣២ ពាន់លានរៀល (២.៤១ពាន់លាន ដុល្លារអាមេរិក) និង ១០.២៨៧ ពាន់លានរៀល (២.៥២ពាន់លាន ដុល្លារអាមេរិក) ដោយបានកើនចំនួន ៥៥% និង ៣.៦៧% រៀងគ្នាធៀបនឹងឆ្នាំ២០០៧ ។

ចំពោះគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុវិញ ធនាគារជាតិនៃកម្ពុជាបានចេញប្រកាសអនុញ្ញាតឱ្យគ្រឹះស្ថានណាដែលមានលក្ខណៈសម្បត្តិគ្រប់គ្រាន់អាចប្រមូលប្រាក់បញ្ញើពីសាធារណជន ដែលអាចធ្វើឱ្យថ្លៃមូលនិធិរបស់គ្រឹះស្ថានមានការថយចុះ ។ អនុបាតសាធនភាពរបស់គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុស្ថិតក្នុងកម្រិត ២០% ចាប់ពីឆ្នាំ ២០០៧ ខ្ពស់ជាងការតម្រូវដោយបទប្បញ្ញត្តិចំនួន១៥% ។ អនុបាតឥណទានមិនដំណើរការស្ថិតក្នុងកម្រិតតិចជាង១% ។ ឥណទាននិងប្រាក់បញ្ញើរបស់គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុមានចំនួន ១.១៣០ ពាន់លានរៀល (២៧៤លានដុល្លារអាមេរិក) និង ២២ពាន់លានរៀល (៥.៤១លានដុល្លារអាមេរិក) ។

សូចនាករប្រុងប្រយ័ត្នមួយចំនួន ដែលធនាគារត្រូវអនុវត្តតាមបានបង្ហាញឱ្យឃើញពីភាពប្រសើរ ដោយធនាគារមានប្រតិបត្តិការអាជីវកម្មជាប្រក្រតី និងពុំមានផលប៉ះពាល់ណាជាសំខាន់ ដែលអាចឱ្យមានការបារម្ភដល់ប្រព័ន្ធធនាគារទាំងមូលទេ ។ ទោះជាយ៉ាងណាក៏ដោយ ធនាគារត្រូវតែប្រកាន់នូវជំហរមួយរឹងមាំ ដើម្បីការពារឱ្យបាននូវហានិភ័យដែលអាចកើតមានឡើង ជាពិសេសនៅក្នុងកាលៈទេសៈនៃវិបត្តិហិរញ្ញវត្ថុជាសកលនេះ ។ ធនាគារជាតិនៃកម្ពុជាក៏មានវិធានការដោះស្រាយចំពោះបញ្ហាកង្វះខាតសាច់ប្រាក់ងាយស្រួលបណ្តោះអាសន្នរបស់ប្រព័ន្ធធនាគារ ដោយអនុញ្ញាតឱ្យគ្រឹះស្ថានធនាគារអាចស្នើសុំឥណទានពីធនាគារជាតិនៃកម្ពុជា ក្រោមរូបភាពជាឥណទានវិបារូបន៍ ។ម្យ៉ាងវិញទៀតជាមួយនឹងការកើនឡើងយ៉ាងឆាប់រហ័សនូវចំនួនគ្រឹះស្ថានធនាគារ នៅឆ្នាំ២០០៨នេះ ធនាគារជាតិនៃកម្ពុជាបានអនុវត្តគោលការណ៍ដើមទុនថ្មី ដោយតម្រូវឱ្យធនាគារពាណិជ្ជបង្កើនដើមទុនពី ៥០ពាន់លានរៀល ដល់ ១៥០ពាន់លានរៀល ឯធនាគារឯកទេស ពី ១០ពាន់លានរៀល ទៅ ៣០ពាន់លានរៀល ដែលជាការរឹតបន្តឹងមួយក្នុងការស្វែងរកនូវភាពប្រកួតប្រជែងមួយពិតប្រាកដក្នុងចំណោមធនាគារដែលបាននិងមានបំណងវិនិយោគនៅកម្ពុជា ។

ជាមួយនឹងកិច្ចការជាច្រើនដែលបានធ្វើកន្លងមក ដូចជាការរៀបចំឱ្យមានបទបញ្ជាមួយចំនួន សម្រាប់ធនាគារអនុវត្ត និងការខិតខំសម្រេចឱ្យបាននូវការអនុវត្តច្បាប់ស្តីពីការប្រឆាំងការសំអាតប្រាក់ និងហិរញ្ញប្បទានភេរវកម្ម ដោយ

បង្កើតឱ្យមានអង្គភាពស៊ើបការហិរញ្ញវត្ថុ ព្រមទាំងអនុវត្តតាមគោលការណ៍ស្នូលសម្រាប់ការត្រួតពិនិត្យ ប្រកបដោយប្រសិទ្ធភាព ។ ដើម្បីឆ្លើយតបទៅនឹងភាពកាន់តែស៊ីជម្រៅនៃវិស័យហិរញ្ញវត្ថុ ធនាគារជាតិនៃកម្ពុជាបានអនុវត្តយ៉ាងហ្មត់ចត់រាល់ទិសដៅ ដែលមានចែងនៅក្នុងយុទ្ធសាស្ត្រអភិវឌ្ឍវិស័យហិរញ្ញវត្ថុឆ្នាំ ២០០៦-២០១៥ ។ ការប្រកួតប្រជែងក្នុងប្រព័ន្ធធនាគារត្រូវបានពង្រឹង ដោយជំរុញឱ្យគ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុខិតខំកសាងសមត្ថភាព និងធ្វើឱ្យកាន់តែប្រសើរឡើងនូវសេវាកម្មរបស់ខ្លួន តាមរយៈការបង្កើតឱ្យមានផលិតផលថ្មីៗនិងទំនើបដូចជា ម៉ាស៊ីនដកប្រាក់ស្វ័យប្រវត្តិ ប័ណ្ណឥណទាន ប័ណ្ណឥណពន្ធ សេវាផ្ទេរប្រាក់តាមទូរស័ព្ទ និង Internet Banking ជាដើម ។ ស្របគ្នាផងដែរ ធនាគារជាតិនៃកម្ពុជានៅតែបន្តការបណ្តុះបណ្តាល និងពង្រឹងសមត្ថភាពមន្ត្រីត្រួតពិនិត្យធនាគារឱ្យកាន់តែមានជំនាញខ្ពស់ឡើង ដើម្បីឆ្លើយតបទៅនឹងការអភិវឌ្ឍយ៉ាងឆាប់រហ័សនៃប្រព័ន្ធធនាគារនិងហិរញ្ញវត្ថុ ។

រាជធានីភ្នំពេញ ថ្ងៃទី ១៣ ខែ សីហា ឆ្នាំ ២០០៩

**ជា ចាន់តូ**

**ទេសាភិបាល ធនាគារជាតិនៃកម្ពុជា**

# មាតិកា

ទំព័រ


តារាងអក្សរកាត់ ....................... v

១~ អន្តរការីយកម្មធនាគារ ....................... ១

២~ ភាពរឹងមាំនៃហិរញ្ញវត្ថុក្នុងវិស័យធនាគារ ....................... ៥

៣~ ការវិវឌ្ឍមីក្រូហិរញ្ញវត្ថុ ....................... ៩

៤~ ការប្រឆាំងការសំអាតប្រាក់ ....................... ១១

ឧបសម្ព័ន្ធទី១: រចនាសម្ព័ន្ធនាយកដ្ឋានត្រួតពិនិត្យ ....................... ១៣

ឧបសម្ព័ន្ធទី២: ទិន្នន័យគ្រឹះស្ថានធនាគារ និងគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ ឆ្នាំ ២០០៨ ....................... ១៤

ឧបសម្ព័ន្ធទី៣: អត្រាការប្រាក់ ....................... ១៥

ឧបសម្ព័ន្ធទី៤: ប្រព័ន្ធធនាគារនៅកម្ពុជា ....................... ១៧

# តារាងអក្សរកាត់

| | |
|---|---|
| ADB | Asian Development Bank |
| AML/CFT | Anti-Money Laundering/Combating the Financing of Terrorism |
| APG | Asia Pacific Group on Money Laundering |
| ATM | Automatic Teller Machines |
| CMA | Cambodian Microfinance Association |
| FATF | Financial Action Task Force |
| FDI | Foreign Direct Investment |
| CAFIU | Cambodian Financial Intelligence Unit |
| GDP | Gross Domestic Product |
| IFC | International Financial Corporation |
| IMF | International Monetary Fund |
| KHR | Khmer Riel |
| MFIs | Microfinance Institutions |
| NBC | National Bank of Cambodia |
| NGO | Non-Governmental Organization |
| NPL | Non-Performing Loan |
| ROA | Return on Assets |
| ROE | Return on Equity |
| THB | Thai Baht |
| USD | US Dollar |

## ១.អន្តរការិយកម្មធនាគារ

វិស័យធនាគារនៅក្នុងប្រទេសកម្ពុជាបានបើកទំព័រថ្មីមួយនៅឆ្នាំ ២០០៨ នៅពេលដែលការកើនឡើង និងការថយចុះកើតមានឡើងនៅពេលតែមួយ ។ ទោះបីជាវិបត្តិពិភពលោកបានកើតឡើងក៏ដោយ ក៏អន្តរការិយកម្មក្នុងវិស័យធនាគារនៅតែបន្តកើនឡើងតាមអត្រាដែលបានរំពឹងទុកនាពាក់កណ្តាលឆ្នាំ ២០០៨ ទន្ទឹមនឹងពេលសញ្ញាណនៃការធ្លាក់ចុះនៅពាក់កណ្តាលឆ្នាំបន្ទាប់ ដែលជាលទ្ធផលនៃផលប៉ះពាល់ពីវិបត្តិហិរញ្ញវត្ថុពិភពលោក ។ ផលប៉ះពាល់រួមសំរាប់ឆ្នាំ ២០០៨ នេះអាចផាត់ទាត់ជាមួយនឹងការរីកចំរើនបន្តិចបន្តួចពីឆ្នាំ ២០០៧ ។ ចំណែកឯអន្តរការិយកម្មនៅឆ្នាំ ២០០៩ ត្រូវបានរំពឹងថានឹងឆ្លងកាត់រយៈពេលលំបាកមួយ ។

ធនាគារមានចំនួន ៣០ នៅចុងឆ្នាំ ២០០៨ ដែលក្នុងនោះមានធនាគារពាណិជ្ជចំនួន ២៤ និង ធនាគារឯកទេសចំនួន៦ ។ ជាមួយគ្នានេះដែរ តំណាងការិយាល័យធនាគារបរទេសមានចំនួន ២ ដែលកំពុងសង្កេតការ ពីការវិវឌ្ឍនៃធុរៈកិច្ចនៅក្នុងប្រទេស ។ ក្រៅពីនេះមានគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុដែលមានអាជ្ញាប័ណ្ណចំនួន ១៨ និងប្រតិបត្តិករ ឥណទានជនបទចំនួន ២៥ ដែលកំពុងធ្វើប្រតិបត្តិការពាសពេញផ្ទៃប្រទេស ក្នុងការផ្តល់សេវាហិរញ្ញវត្ថុខ្នាតតូចដល់ប្រជាជននៅតាមជនបទ និងនៅតាមជាយក្រុង ។ ការកើនឡើងនៃគ្រឹះស្ថានធនាគារ ការធ្វើទំនើបកម្មនៃផលិតផល និងសេវារបស់ធនាគារបាននាំទៅដល់ភាពប្រសើរឡើងនៃអន្តរការិយកម្ម ក៏ដូចជាជំនឿទុកចិត្តនៅក្នុងវិស័យធនាគារ ។

ចំនួនអ្នកដាក់ប្រាក់បញ្ញើនៅក្នុងវិស័យធនាគារមានប្រមាណ ៧០០,០០០ នាក់ ដែលកើនឡើងជិតពីរដងធៀបនឹងឆ្នាំ ២០០៧ ។ កំណើននៃការប្រកួតប្រជែង ការបង្កើតផលិតផលហិរញ្ញវត្ថុថ្មី និងភាពងាយស្រួលនៃសេវាកម្មបានជំរុញឱ្យមានការចូលរួមក្នុងវិស័យធនាគារកាន់តែច្រើនឡើង ។ ទោះបីជាមានការកើនឡើងយ៉ាងច្រើននូវចំនួនគណនី ប៉ុន្តែចំនួនជាក់លាក់នៃប្រាក់បញ្ញើរបស់អតិថិជនមានការកើនឡើងត្រឹមតែ ៤% ប៉ុណ្ណោះ បើប្រៀបធៀបទៅនឹង ៧៥% នៅឆ្នាំ ២០០៧ ។ នេះគឺជាករណីដែលធ្វើឱ្យមានកំណើនប្រាក់បញ្ញើរបស់អតិថិជននៅឆ្នាំ ២០០៨ រហូតដល់វិបត្តិហិរញ្ញវត្ថុពិភពលោកបានចូលដល់ទឹកដីកម្ពុជា ជាពិសេសក្នុងវិស័យធនាគារ ដែលបានកត់សំគាល់តាមរយៈការធ្លាក់ចុះនូវប្រាក់បញ្ញើអតិថិជនមួយចំនួនធំ និងលំហូរចេញនូវមូលធននៅពេលដែលវិស័យធនាគារបានទទួលផលប្រយោជន៍ច្រើនបំផុតពីការហូរចូលនៃមូលធន ។

**ក្រាហ្វទី១: ចំនួនអ្នកដាក់ប្រាក់បញ្ញើ**



ជនជាតិកូរ៉េ ចិន ថៃ និងម៉ាឡេស៊ី គឺជាវិនិយោគិនសំខាន់ៗនៅក្នុងប្រទេសកម្ពុជា ប៉ុន្តែប្រទេសរបស់ពួកគេក៏ត្រូវបានប៉ះទង្គិចដោយវិបត្តិសេដ្ឋកិច្ចដែរ។ ភាគច្រើននៃវិនិយោគិនទាំងនោះបានបង្ខំចិត្តកាត់បន្ថយការវិនិយោគ ឬ បង្វែរទុនសំរាប់ការវិនិយោគនោះទៅប្រទេសរបស់ពួកគេវិញ។ ម៉្យាងទៀតនៅចុងឆ្នាំ២០០៨ តម្លៃរូបិយប័ណ្ណសំខាន់ៗភាគច្រើននៅអាស៊ីបានធ្លាក់ចុះ បើធៀបទៅនឹងប្រាក់ដុល្លារអាមេរិក ដែលជាហេតុបង្កឱ្យមានឱកាសដល់វិនិយោគិនបរទេសក្នុងការទាញយកផលចំណេញពីអត្រាប្តូរប្រាក់ ដោយការបង្វិលប្រាក់ដុល្លារអាមេរិកពីប្រទេសដែលប្រើប្រាស់ប្រាក់ដុល្លារអាមេរិក ដូចជា ប្រទេសកម្ពុជាទៅប្រទេសពួកគេវិញ ។ វាបានបង្ហាញយ៉ាងច្បាស់លាស់ដោយការធ្លាក់ចុះនូវប្រាក់បញ្ញើរបស់អតិថិជនពីបណ្តាធនាគារក្នុងត្រីមាសចុងក្រោយនៃឆ្នាំ ២០០៨។

**ក្រាហ្វទី២: ប្រាក់បញ្ញើរបស់ធនាគារ និងគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ**




នៅខាងផ្នែកឥណទាន ចំនួនអ្នកខ្ចីបានកើនឡើង១៦% ដែលគិតលើតំលៃជាក់ស្តែង លើឥណទានផ្តល់ឱ្យអតិថិជនមានចំនួនដល់ ៩.៨៣២ពាន់លានរៀល ឬក៏កើនឡើង ៥០% បើប្រៀបធៀបទៅនឹងឆ្នាំមុន។ នេះគឺជាកត្តាមួយដែលគ្រប់វិស័យទាំងអស់នៃសេដ្ឋកិច្ចមានការងើបឡើង និងតំរូវការយ៉ាងខ្លាំងនូវមូលនិធិជាច្រើនដើម្បីការអភិវឌ្ឍ ។ ភាគច្រើននៃការពង្រីកឥណទាន គឺទាក់ទងនឹងវិស័យពាណិជ្ជកម្មលក់ដុំ លក់រាយ និងវិស័យសេវាកម្មដែលរួមមាន សណ្ឋាគារ ភោជនីយដ្ឋាន ទូរគមនាគមន៍ ប្រព័ន្ធផ្សព្វផ្សាយ និងសេវាកម្មផ្សេងៗដែលមិនមែនហិរញ្ញវត្ថុ។ វិស័យកម្មន្តសាល ក៏ទទួលបាននូវហិរញ្ញប្បទានធនាគារមួយផ្នែកធំ ដែលជាលទ្ធផលនៃវិស័យនេះ គឺបានបង្កើតនូវការងារយ៉ាងច្រើន។ អាគារពាណិជ្ជកម្ម អាគារស្នាក់នៅ និងការសាងសង់ ក៏បានទទួលនូវផលប្រយោជន៍យ៉ាងច្រើនពីការកើនឡើងយ៉ាងឆាប់រហ័សពីវិស័យឥណទានផងដែរ ។ ការកើនឡើងនៃវិស័យឥណទានទៅលើវិស័យអចលនទ្រព្យ គឺជាកង្វល់ចំបងសំរាប់អ្នកត្រួតពិនិត្យ ព្រោះការកើនឡើងខ្លាំងនៃវិស័យអចលនទ្រព្យអាចនាំឱ្យមានហានិភ័យដល់ប្រព័ន្ធធនាគារ។ ក្រៅពីការកើនឡើងយ៉ាងឆាប់រហ័សនៃឥណទាន ស្របពេលជាមួយការកើនឡើងនៃតម្លៃប្រេង និងការធ្លាក់ចុះនៃតម្លៃរូបិយប័ណ្ណដុល្លារអាមេរិកនៅដើមឆ្នាំ ២០០៨ បានជំរុញឱ្យមានការកើនឡើងនូវអតិផរណារហូតដល់ចំណុចកំពូលនៅក្នុងត្រីមាសទី២ ឆ្នាំ ២០០៨ ។

ប្រឈមមុខទៅនឹងបញ្ហាទាំងនេះ ធនាគារជាតិនៃកម្ពុជា ដែលជាអាជ្ញាធររូបិយវត្ថុ និងជាអ្នកត្រួតពិនិត្យបានយល់ឃើញពីភាពចាំបាច់ដើម្បីកាត់បន្ថយល្បឿននៃការឱ្យខ្ចី។ ធនាគារបានដាក់ចេញនូវវិធានការសុវត្ថិភាពមួយចំនួនដូចជា ក៏រិតពិដាន ១៥% លើការឱ្យខ្ចីលើវិស័យអចលនទ្រព្យ បង្កើន ២ដង នៃប្រាក់បម្រុងកាតព្វកិច្ចរហូតដល់ ១៦% ចំពោះរាល់ប្រាក់បញ្ញើ និងកម្ចីផ្សេងៗរបស់ធនាគារ ព្រមទាំងជំរុញឱ្យមានការឃ្លាំមើលលើការផ្តល់ឥណទានទៅឱ្យវិស័យសេដ្ឋកិច្ច ក៏ដូចជាធានាឱ្យបាននូវគុណភាពរបស់ឥណទាន។

**ក្រាហ្វទី៣: ចំនួនអ្នកខ្ចីប្រាក់**




លទ្ធផលទទួលបាន គឺដូចបានរំពឹងទុក ដោយធ្វើឱ្យកំណើនឥណទានមានការថយចុះនៅចុងឆ្នាំ២០០៨ ជាពិសេសដោយសារតែបទបញ្ញាប្រុងប្រយ័ត្នដែលចេញដោយអាជ្ញាធរត្រួតពិនិត្យ។ ជាមួយគ្នានេះដែរ ជ្រុងមួយទៀតនៃបញ្ហា គឺស្តែងឱ្យឃើញពី "ផលប៉ះពាល់ពីវិបត្តិហិរញ្ញវត្ថុពិភពលោក" ។ វិស័យដែលសំខាន់ៗនៅក្នុងសេដ្ឋកិច្ច គឺការនាំចេញវាយនភណ្ឌ វិស័យទេសចរណ៍ សំណង់ និងអចលនទ្រព្យ ដែលត្រូវបានប៉ះទង្គិចដោយវិបត្តិហិរញ្ញវត្ថុពិភពលោក ហើយតម្រូវការមូលនិធិបន្ថែមដើម្បីទ្រទ្រង់និរន្តភាពធុរៈកិច្ច ។ ប៉ុន្តែឥណទានរបស់ធនាគារ គឺជាវិធីតែមួយគត់នៃការផ្តល់ហិរញ្ញប្បទាន ដោយសារតែកង្វះទីផ្សារមូលធន និងរូបិយវត្ថុដែលធ្វើឱ្យកំនើនសេដ្ឋកិច្ចមានការកើនឡើងកាន់តែយឺត។

**ក្រាហ្វទី៤: ឥណទានរបស់ធនាគារ និងគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ**



ក្រោយពីបានស្វែងយល់ពីបញ្ហានេះ ធនាគារជាតិនៃកម្ពុជា បានដាក់ចេញនូវវិធានការគាំទ្រដល់ការអភិវឌ្ឍន៍សេដ្ឋកិច្ចដោយសំរួលដល់លំហូរនៃឥណទានក្នុងវិស័យសេដ្ឋកិច្ច ។ ការដាក់ពិដានលើវិស័យអចលនទ្រព្យ និងប្រាក់បម្រុងកាតព្វកិច្ចត្រូវបានលុបបំបាត់ និងប្រាក់បម្រុងកាតព្វកិច្ចត្រូវបានបន្ថយមកនូវត្រឹមតែ ១២% នៅដើមឆ្នាំ២០០៩ ។ ទន្ទឹមនឹងនេះដែរ មានតែប្រាក់បញ្ញើរបស់អតិថិជនទេ ដែលត្រូវកំណត់ឱ្យតំកល់ប្រាក់បម្រុងកាតព្វកិច្ចទន្ទឹមពេលដែលការបណ្តាក់ទុន និងប្រាក់កម្ចីរបស់ធនាគារមិនត្រូវបានរាប់បញ្ចូលក្នុងការគណនាប្រាក់បម្រុងកាតព្វកិច្ច ។ បច្ចេកទេសក្នុងការរាយការណ៍ និងការតាមដាននូវទុនបម្រុង ក៏ត្រូវបានកែសំរួលដើម្បីផ្តល់ភាពងាយស្រួលដល់ធនាគារក្នុងការគ្រប់គ្រងសាច់ប្រាក់ងាយស្រួលរបស់ពួកគេ ។ គំនិតផ្តួចផ្តើមទាំងនេះ គឺសំរាប់បន្ថយសំពាធនៃសាច់ប្រាក់ងាយស្រួលរបស់ធនាគារដើម្បីផ្តល់លទ្ធភាពដល់ពួកគេក្នុងការពង្រីកការផ្តល់ឥណទានដល់អតិថិជន ក៏ដូចជាដាក់បញ្ចូលមូលនិធិបន្ថែមដើម្បីពន្លឿននូវរង្វិលជុំរបស់សេដ្ឋកិច្ច និងជំរុញដល់ការលូតលាស់របស់សេដ្ឋកិច្ច ។ ការដកចេញនូវពិដានឥណទានចំពោះវិស័យអចលនទ្រព្យ មិនមែនមានន័យថា អាជ្ញាធរត្រួតពិនិត្យអនុញ្ញាតឱ្យធនាគារផ្តល់ឥណទានបន្ថែមទៅលើវិស័យនេះ ដោយគ្មានការគ្រប់គ្រងនោះទេ ។ ជាការពិតណាស់ សហគមន៍ធនាគារជារួមបានយល់ដឹងអំពីហានិភ័យពីការវិនិយោគលើវិស័យអចលនទ្រព្យ ហើយបានជ្រើសយកនូវវិធានការដ៏សមស្របសំរាប់កាត់បន្ថយហានិភ័យ ។ មានតែធនាគារមួយចំនួនតូចប៉ុណ្ណោះដែលធ្វើអាជីវកម្មផ្ទាល់ជាមួយការវិនិយោគលើវិស័យអចលនទ្រព្យ និងការផ្តល់ហិរញ្ញប្បទាននិក្ខេបត្រូវបានតាមដានយ៉ាងហ្មត់ចត់ ។ នៅចុងឆ្នាំ ២០០៨ ការផ្តល់ឥណទានទៅលើវិស័យអចលនទ្រព្យនៅ ក្នុងប្រព័ន្ធធនាគារមានចំនួន ១៤% នៃសំពាតឥណទានទាំងមូល ខណៈពេលដែលឥណទានទៅលើវិស័យសាងសង់មាន ចំនួន ៨% បន្ថែមទៀត ។

**ក្រាហ្វទី៥: ឥណទានតាមប្រភេទជំនួញ**



## ២.ភាពរឹងមាំនៃហិរញ្ញវត្ថុក្នុងវិស័យធនាគារ

ចាប់តាំងពីមានកម្មវិធីកំណែទម្រង់នៅឆ្នាំ២០០០ មក សុខភាពនិងភាពរឹងមាំរបស់ប្រព័ន្ធធនាគារមានភាពប្រសើរឡើងជាបន្តបន្ទាប់ ។ ដើមទុនរបស់ធនាគារក៏ត្រូវបានធ្វើឱ្យប្រសើរឡើង រចនាសម្ព័ន្ធអភិបាលកិច្ចក៏បានធ្វើបច្ចុប្បន្នកម្មដោយអនុលោមតាមការអនុវត្តអន្តរជាតិ ផលិតផលនិងសេវារបស់ធនាគារត្រូវបានពង្រីកជាបន្តបន្ទាប់ ។ ឆ្នាំ២០០៨ គឺជាឆ្នាំដែលមានការកើនឡើងយ៉ាងខ្លាំង និងថយចុះយ៉ាងឆាប់រហ័សនៃអន្តរការីយកម្មនៅក្នុងប្រព័ន្ធធនាគារ ។ ទោះជាយ៉ាងណា សុខភាពនិងភាពរឹងមាំរបស់ធនាគារនៅតែមានភាពខ្លាំង ដោយមានការបញ្ជាក់ពីសូចនាករនៃការប្រព្រឹត្តល្អ និងការអនុវត្តបាននូវបទបញ្ជាប្រុងប្រយ័ត្ននានា។

**ក្រាហ្វទី៦: អនុបាតសាធនភាព និងអនុបាតសាច់ប្រាក់ងាយស្រួល**




រចនាសម្ព័ន្ធរបស់តារាងតុល្យការនៅក្នុងប្រព័ន្ធធនាគារ បានបង្ហាញនូវការផ្លាស់ប្តូរបន្តិចបន្តួចដូចជា មូលធនផ្ទាល់សរុបបានកើនឡើងពី ១៧% ទៅ ២២% នៃទ្រព្យសកម្មសរុប បើធៀបនឹងឆ្នាំមុន ។ មានកត្តាពីរសំរាប់ការបកស្រាយនូវបាតុភូតនេះ។ កត្តាទី១ គឺការដាក់បញ្ចូលបន្ថែមនូវដើមទុនពីធនាគារថ្មី។ នៅក្នុងឆ្នាំ ២០០៨ ធនាគារចំនួន ៦ បន្ថែមទៀតបានចូលទៅក្នុងប្រព័ន្ធ ដែលក្នុងនោះរួមមានធនាគារពាណិជ្ជចំនួន ៥ ( ធនាគារ វីអាយភី បានទទួលអាជ្ញាប័ណ្ណរួចក៏សុំជំរះបញ្ជីដោយស្ម័គ្រចិត្ត) និងធនាគារឯកទេសចំនួន១ ។ ជាមួយនឹងការប្រកួតប្រជែងរវាងធនាគារជាច្រើន អតិថិជននឹងទទួលបាននូវផលប្រយោជន៍ពីការចំណាយថ្លៃដើមទាប និងទទួលបានសេវាកម្មល្អប្រសើរជាងមុន ។ ចាប់តាំងពីដើមឆ្នាំ អត្រាការប្រាក់លើការឱ្យខ្ចីចងការរបស់ធនាគារភាគច្រើនបានថយចុះជាលំដាប់ ខណៈពេលដែលអត្រាការប្រាក់នៃប្រាក់បញ្ញើរបស់អតិថិជនបានកើនឡើងជាបន្តបន្ទាប់ ។ ធនាគារខ្លះមិនជ្រើសយកការប្រកួតប្រជែងដោយផ្អែកលើការចំណាយថ្លៃដើមទេ ប៉ុន្តែគេជ្រើសយកការប្រកួតប្រជែងដោយសេវាជំនួសវិញ ។ កំណើនចំនួននៃការពង្រីកបណ្តាញនៅក្នុងមជ្ឈ

មណ្ឌល ទីក្រុងសំខាន់ៗ និងតំបន់ជាយក្រុងក៏ស្ថិតនៅក្រោមការអង្កេតផងដែរ។ រួមជាមួយគ្នានេះ ក៏មាននូវផលិតផលថ្មីៗ ដូចជា ប្រតិបត្តិការធនាគារតាមអ៊ីនធឺណេត ប័ណ្ណឥណពន្ធ និងប័ណ្ណឥណទាន ឥណទានសំរាប់ទិញរថយន្ត ឥណទានសំរាប់ទិញផ្ទះ និងឥណទានសំរាប់ការប្រើប្រាស់ផ្សេងទៀត ដែលបានផ្តល់កាន់តែច្រើនឡើងទៅឱ្យសាធារណជន ។ កត្តាទីពីរ គឺការកើនឡើងយឺតនៃការដាក់ប្រាក់បញ្ញើរបស់អតិថិជន បើប្រៀបធៀបទៅឆ្នាំមុន ។ ការកើនឡើងនៃការដាក់ប្រាក់បញ្ញើរបស់អតិថិជនមិនសមស្របនឹងការកើនឡើងយ៉ាងខ្លាំងនៃការផ្តល់ឥណទាននោះទេ ។ ធនាគារចាំបាច់ត្រូវបង្កើនមូលធន ឬខ្ទីមូលនិធិបន្ថែមទៀត ។

**ក្រាហ្វទី៧: និន្នាការអត្រាការប្រាក់ (សំរាប់ប្រាក់ដុល្លា)**




សូចនាករពីរដែលត្រូវបានគេស្គាល់សំរាប់មើលលើប្រព័ន្ធធនាគារ គឺអនុបាតសាច់ប្រាក់ងាយស្រួល និងអនុបាតសាធនភាព។ អនុបាតសាច់ប្រាក់ងាយស្រួលបានធ្លាក់ចុះដល់ ៨១% ប៉ុន្តែស្ថិតនៅលើកំរិតបទបញ្ញត្តិអប្បបរមា ៥0% ។ ការកើនឡើងយ៉ាងខ្លាំងនៃការផ្តល់ឥណទាន និងការកើនឡើងយឺតនៃការដាក់ប្រាក់បញ្ញើបានធ្វើឱ្យរាំងស្ទះដល់ស្ថានភាពសាច់ប្រាក់ងាយស្រួលនៅក្នុងប្រព័ន្ធធនាគារ ។ ដោយប្រទេសកម្ពុជា គឺជាប្រទេសដែលសេដ្ឋកិច្ចពឹងផ្អែកលើសាច់ប្រាក់ ដូច្នេះការបញ្ចេញឥណទានយ៉ាងឆាប់រហ័ស គឺនាំឱ្យមាននូវភាពតិចតួចនៃទ្រព្យសកម្មងាយស្រួល ខណៈពេលដែលការដាក់ប្រាក់បញ្ញើមានល្បឿនយឺត ។ អនុបាតសាធនភាពបានកើនឡើងពី ២៤% នៅឆ្នាំ ២00៧ មកដល់ ២៨% ។ ភាពប្រសើរឡើងនៃមូលធននិងមូលនិធិផ្ទាល់សុទ្ធរបស់ធនាគារ គឺដោយសារតែការបន្ថែមនូវមូលធនរបស់ធនាគារថ្មីៗ និងធនាគារចាស់បានជួយជំរុញអនុបាតសាធនភាព ។ ធនាគារដែលទើបបង្កើតថ្មីហាក់ដូចជាមានអនុបាតសាធនភាពខ្ពស់ជាងធនាគារចាស់ដោយគេទើបតែចូលក្នុងទីផ្សារ និងទទួលបានចំណែកទីផ្សារតូចនៃសំពាតឥណទាន។ ប៉ុន្តែធនាគារធំៗភាគច្រើនរក្សាទុកអនុបាតនៅលើកំរិតនៃបទបញ្ញត្តិតែបន្តិចប៉ុណ្ណោះ ដោយសារតែពួកគេចង់បង្កើនប្រាក់ចំណេញឱ្យបានខ្ពស់។

### ក្រាហ្វទី៨: ឥណទានមិនដំណើរការ និង សម្ព័ន្ធញាតិ




តាមរយៈការគិតពិចារណាឱ្យបានស៊ីជំរៅលើសំពាធឥណទាន សូចនាករបានផ្តល់ឱ្យនូវទ្រព្យសកម្មដែល មានគុណភាពល្អមួយ ។ អនុបាតនៃឥណទានមិនដំណើរការនៅចុងឆ្នាំ ២០០៨ មានចំនួន ៣.៦៨% ដែលចំនួននេះចាត់ទុកថានៅមានកំរិតទាប ទោះបីជាប្រព័ន្ធធនាគារមានកំណើនឥណទានយ៉ាងខ្លាំងក៏ដោយ ។

កម្មវិធីកសាងសមត្ថភាព គឺជាការងារអាទិភាពមួយរបស់ធនាគារជាតិនៃកម្ពុជា ដោយមានការបណ្តុះបណ្តាលនៅនឹងកន្លែង និងការបណ្តុះបណ្តាលនៅបរទេស ។ ទន្ទឹមនឹងនេះដែរ ការផ្តួចផ្តើមគំនិតជាច្រើនត្រូវបានបង្កើតឡើងដើម្បីកែលំអលើបទបញ្ញាប្រុងប្រយ័ត្ន ឱ្យស្របជាមួយនឹងការអនុវត្តជាអន្តរជាតិ ។ បទបញ្ញាថ្មីលើការចាត់ថ្នាក់ឥណទាន និងការធ្វើសំវិធានធនត្រូវបានអនុម័ត សំរាប់ការអនុវត្តដែលនឹងផ្តល់ឱ្យនូវឧបករណ៍ដ៏ល្អប្រសើរឡើង សំរាប់ការវាយតំលៃលើសំពាធឥណទាន ។ បច្ចេកទេសសំរាប់ពិនិត្យមើលឡើងវិញលើឥណទាន គឺកំពុងត្រូវបានផ្ទេរពីអ្នកត្រួតពិនិត្យធនាគារដែលមានបទពិសោធន៍នៅលើពិភពលោកទៅអ្នកត្រួតពិនិត្យក្មេងខ្ចី ប៉ុន្តែជាអ្នកមានសមត្ថភាពនិងចំណង់ក្នុងការសិក្សាយ៉ាងខ្លាំងរបស់ធនាគារជាតិនៃកម្ពុជា ។

ការឱ្យខ្ចីចំពោះសម្ព័ន្ធញាតិស្ថិតនៅកំរិតតិចជាង ២% នៃមូលនិធិផ្ទាល់សុទ្ធ (កំរិតអតិបរមា ១០%)។ នេះក៏ជាលទ្ធផលមួយទៀតនៃការរឹតបន្តឹងបទបញ្ញត្តិប្រុងប្រយ័ត្ន ដើម្បីជៀសវាងការបង្វិលដើមទុនទៅឱ្យភាគទុនិក ក៏ដូចជាអ្នកគ្រប់គ្រងថ្នាក់ខ្ពស់របស់ធនាគារផងដែរ ។

**ក្រាហ្វទី៩: ចំណូលពីមូលធន និងចំណូលពីទ្រព្យសកម្ម**




សរុបសេចក្តីមក ចំណូលពីមូលធន (ROE) សំរាប់ប្រព័ន្ធធនាគារបានធ្លាក់ចុះមកដល់ ១៣% ពី ១៦% នៅឆ្នាំ ២០០៧។ ការធ្លាក់ចុះនេះគឺបណ្តាលមកពីការជះឥទ្ធិពលពីធនាគារថ្មីចំនួន ៦ ដែលបានបង្កើតឡើងក្នុងអំឡុងឆ្នាំ ២០០៨។ ធនាគារទាំងនោះបានខាតក្នុងប្រតិបត្តិការដំបូងរបស់ពួកគេ ។ ទោះជាយ៉ាងណាក៏ដោយ វាក៏ស្ថិតនៅក្នុងកំរិតមួយដែលអាចទទួលយកបានដែរ ព្រោះថាធនាគារបានបង្ហាញនូវប្រសិទ្ធភាពនៃការប្រើប្រាស់មូលធន ក៏ដូចជាមូលនិធិដែលប្រមូលបានពីការដាក់ប្រាក់បញ្ញើ និងការឱ្យខ្ចីរបស់ខ្លួន ។ ការឱ្យខ្ចីបានកើនឡើងចំនួន ៥៥% បើប្រៀបធៀបទៅនឹងឆ្នាំ ២០០៧ ។ រីឯចំណូលពីទ្រព្យសកម្ម (ROA) មានស្ថេរភាពក្នុងរង្វង់ ២.៨% បើប្រៀបធៀបទៅនឹងពីរឆ្នាំមុន។ ប្រាក់ចំណេញចំបងពីទ្រព្យសកម្មរបស់ធនាគារជាក់ស្តែង គឺបានមកពីការផ្តល់ឥណទានដែលមានចំនួន ៥៧% នៃទ្រព្យសកម្មសរុប ហើយមួយផ្នែកទៀត គឺបានមកពីការដាក់ប្រាក់បញ្ញើនៅធនាគារជាតិនៃកម្ពុជាដែលមានចំនួន ២៣% នៃទ្រព្យសកម្មសរុប។ ដោយសារតែមិនទាន់មានការអភិវឌ្ឍផ្នែកទីផ្សារហិរញ្ញវត្ថុ ជាពិសេសគឺការខ្វះខាតនូវទីផ្សារអន្តរធនាគារក្រៅពីការឱ្យខ្ចី ធនាគារបានវិនិយោគមូលនិធិដោយការដាក់ប្រាក់បញ្ញើនៅធនាគារជាតិនៃកម្ពុជា ដើម្បីទទួលបានការប្រាក់ ។ ដូច្នេះប្រសិទ្ធភាពនៃការប្រើប្រាស់ទ្រព្យសកម្មដើម្បីរកប្រាក់ចំណេញ គឺទទួលបានមកពីសកម្មភាពនៃ ការឱ្យខ្ចី ដែលជាលទ្ធផលធ្វើឱ្យចំណូលការប្រាក់មានការកើនឡើងយ៉ាងច្រើន ។

## ៣-ការអភិវឌ្ឍមីក្រូហិរញ្ញវត្ថុ

វិស័យមីក្រូហិរញ្ញវត្ថុនៅកម្ពុជាមានការអភិវឌ្ឍដោយសន្ទុះខ្លាំងនៅឆ្នាំ ២០០៨ ។ គិតត្រឹមដំណាច់ឆ្នាំ ២០០៨ គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុមានអាជ្ញាប័ណ្ណចំនួន ១៨ និងប្រតិបត្តិករឥណទានជនបទចុះបញ្ជីមានចំនួន ២៦ ដែលក្នុងនោះគ្រឹះស្ថានទើបតែចុះបញ្ជីចំនួន ២ និងគ្រឹះស្ថានចំនួន ១ ត្រូវបានបញ្ចុះថ្នាក់ពីគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ ។ សមតុល្យឥណទានប្រចាំឆ្នាំ ២០០៨ មានការកើនឡើង ៨១% ដល់ចំនួន ១.១៦១,៧៣ ពាន់លានរៀល ប្រៀបធៀបទៅនឹងឆ្នាំ ២០០៧ ដែលបង្ហាញឱ្យឃើញពីកំណើនឥណទានដ៏គួរឱ្យកត់សម្គាល់ ដោយសារមានកំណើនដើមទុន និងកម្ចីក្នុងនិងក្រៅប្រទេស ។ ប្រជាជននៅតាមជនបទកាន់តែច្រើន បានទទួលចំណេះដឹងទាក់ទងនឹងវិស័យមីក្រូហិរញ្ញវត្ថុ ហើយជាលទ្ធផលបានផ្ដល់ជំនឿទុកចិត្តកាន់តែខ្លាំងមកលើឥណទានមីក្រូហិរញ្ញវត្ថុ ដែលឆ្លុះបញ្ចាំងតាមរយៈកំណើនអតិថិជនប្រចាំឆ្នាំចំនួន ៣៦% (៦២៤.០៨៩ នាក់ ក្នុងឆ្នាំ ២០០៧ និង ៨៥២.០៩០ នាក់ ក្នុងឆ្នាំ ២០០៨) ។

ប្រាក់បញ្ញើសរុបមានចំនួន ២៦ ពាន់លានរៀល កើនឡើងចំនួន ៧% ហើយចំនួនអ្នកដាក់ប្រាក់បញ្ញើមាន ១៥៥.២៩១ នាក់ កើនឡើងចំនួន៥% ពីឆ្នាំ ២០០៧ ។ កំណើននឹងអាចមានច្រើនជាងនេះ ប្រសិនបើគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ មិនបានកាត់បន្ថយនូវសំពាធប្រាក់បញ្ញើរបស់ខ្លួន ដើម្បីអនុលោមទៅតាមប្រកាសរបស់ធនាគារជាតិនៃកម្ពុជាស្ដីពីការផ្ដល់អាជ្ញាប័ណ្ណទទួលប្រាក់បញ្ញើពីសាធារណជនរបស់គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ ដោយមិនអនុញ្ញាតិឱ្យគ្រឹះស្ថានប្រមូលប្រាក់បញ្ញើឡើយ ប្រសិនបើគ្រឹះស្ថានពុំមានអាជ្ញាប័ណ្ណទទួលប្រាក់បញ្ញើទេ ។

យោងតាមប្រកាសរបស់ធនាគារជាតិនៃកម្ពុជា គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុត្រូវរក្សាអនុបាតសាធនភាព ឱ្យបានយ៉ាងតិច ១៥% ហើយគិតមកត្រឹមដំណាច់ឆ្នាំ ២០០៨ អនុបាតសាធនភាពរបស់គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុជាមធ្យមស្ថិតនៅកម្រិត ២០,៣៥% មូលនិធិផ្ទាល់មានការកើនឡើងយ៉ាងសម្បើមចំនួន ៩៥% ដែលមានសន្ទុះ លឿនជាងកំណើនឥណទានដែលមានចំនួន ៨១% ។ ម្យ៉ាងវិញទៀត សម្រាប់ជាការគាំទ្រប្រតិបត្តិការរបស់ខ្លួន គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ ពឹងផ្អែកយ៉ាងខ្លាំងទៅលើបំណុល ហើយបើគិតត្រឹមចុងឆ្នាំ ២០០៨ បំណុលរបស់គ្រឹះស្ថានសរុបបានកើនឡើង ១០២% ដែលស្ទើរតែទាំងស្រុងទទួលបានពីបរទេស ។ ក្នុងគោលបំណងផ្ដល់លទ្ធភាពឱ្យគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ អាចគៀងគរធនធានក្នុង ស្រុកបាន ធនាគារជាតិនៃកម្ពុជាបានចេញប្រកាសថ្មីស្ដីពីការផ្ដល់អាជ្ញាប័ណ្ណទទួលប្រាក់បញ្ញើពីសាធារណជន សម្រាប់គ្រឹះស្ថានណាដែលមានបំណងប្រមូលប្រាក់បញ្ញើ ។ យ៉ាងណាមិញ គិតមកដល់ដំណាច់ឆ្នាំមិនទាន់មានគ្រឹះស្ថានណាមួយទទួលបានអាជ្ញាប័ណ្ណនេះនៅឡើយទេ ។

វិស័យមីក្រូហិរញ្ញវត្ថុ ដែលមានសាច់ប្រាក់ងាយស្រួលខ្ពស់ ដោយសារតែទ្រព្យសកម្មភាគច្រើនមានរយៈពេលខ្លី និងដោយសារតែគ្រឹះស្ថានមានប្រាក់បញ្ញើតិច ដូចដែលមានបង្ហាញនៅក្នុងរូបភាពដូចខាងក្រោម៖

## ក្រាហ្វទី១០: អនុបាតសាច់ប្រាក់ងាយស្រួល




ក្នុងឆ្នាំ ២០០៨ អនុបាតបំណុលហួសកាលកំណត់ស្ថិតនៅកម្រិត ០,៤២% ក្នុងខណៈដែលសមតុល្យ ឥណទានសរុបកើនឡើងគួរឱ្យកត់សម្គាល់ចំនួន ៨១% (រូបភាពនៅទំព័របន្ទាប់) ។

អត្រាការប្រាក់ឥណទាន របស់គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ ជាញឹកញាប់តែងតែជាបញ្ហាចំរូងចំរាស់ក្នុងចំណោមអ្នកដែលមានអត្ថប្រយោជន៍ពាក់ព័ន្ធ ។ បញ្ហានេះតែងត្រូវបានលើកឡើងនៅក្នុងវេទិកាសាធារណៈ ហើយត្រូវបានចាត់ទុកថានៅតែមានកំរិតខ្ពស់ ។ ទោះបីជាមានទស្សនៈបែបនេះក៏ដោយ យ៉ាងណាមិញបើយើងក្រឡេកមើលទៅលើនិន្នាការនៃអត្រាការប្រាក់ឥណទាននៅតែបន្តថយចុះជាបន្តបន្ទាប់ ។ អត្រាការប្រាក់ឥណទានមានការថយចុះក្នុងនោះអត្រាការប្រាក់ឥណទានជាប្រាក់រៀលបានថយចុះចំនួន ៧% និងជាប្រាក់ដុល្លារបានថយចុះចំនួន ២% បើប្រៀបធៀបទៅនឹងឆ្នាំ ២០០៧ ។

## ក្រាហ្វទី១១: ឥណទានមិនដំណើរការ



អត្រាការប្រាក់នៅតែបន្តធ្លាក់ចុះជាបន្តបន្ទាប់ ដោយសារតែការប្រកួតប្រជែងស្មើភាពនៅក្នុងទីផ្សារការអភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធរូបវ័ន្ត ក៏ដូចជាការពង្រឹងការគ្រប់គ្រងផ្ទៃក្នុង ជាពិសេសការគ្រប់គ្រងថ្លៃដើម ។

| បរិយាយ | ២០០៧ | ២០០៨ | បំរែបំរួល |
|---|---|---|---|
| ឥណទានជាប្រាក់រៀល | ៣.២៦% | ៣.០២% | -៧% |
| ឥណទានជាប្រាក់ដុល្លារ | ២.៤៩% | ២.៤៣% | -២% |
| ឥណទានជាប្រាក់បាត | ៣.១៣% | ៣.១៣% | 0% |

នៅក្នុងឆ្នាំ ២០០៨ ទ្រព្យសកម្មសរុបរបស់គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ មានការកើនឡើងចំនួន ៧៨% និងមូលនិធិសរុបកើនឡើងចំនួន ៦៥% ។ ទន្ទឹមនឹងនេះប្រាក់ចំណេញសុទ្ធប្រចាំឆ្នាំកើនឡើងចំនួន ៦0% ។ ចំណូលធៀបនឹងទ្រព្យសកម្មមានចំនួន ៤.៩៩% និងចំណូលធៀបនឹងមូលនិធិមានចំនួន ១៩.0២% បើធៀបនឹងឆ្នាំ ២០០៧ មានចំនួន ៥.៣៧% និង ១៩.៦៧% រៀងគ្នា ។ ចាប់តាំងពីពាក់កណ្តាលឆ្នាំ ២០០៨ លទ្ធភាពរកប្រាក់ចំណេញរបស់គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ មានការថយចុះ ដោយសារតែការធ្លាក់ចុះនៃសកម្មភាពអាជីវកម្មខ្នាតតូច ជាពិសេសនៅតាមទីជនបទដែលអាចប៉ះពាល់ដល់លទ្ធភាពនៃការសងបំណុលរបស់អតិថិជន ។

ប្លង់គណនីថ្មីក៏ត្រូវបានដាក់ឱ្យគ្រប់គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុអនុវត្ត ។ ប្លង់គណនីថ្មីនេះនឹងធ្វើឱ្យកាន់តែប្រសើរឡើងនូវការចុះកិច្ចបញ្ជិការបស់គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ និងឈានទៅដល់ការអនុវត្តគណនេយ្យឱ្យកាន់តែមានភាពត្រឹមត្រូវ និងសុក្រឹត្យ ។ ការអនុវត្តយ៉ាងពេញលេញនូវប្លង់គណនីដែលបានកំណត់ខាងលើ គឺជាលក្ខណៈវិនិច្ឆ័យមួយដើម្បីទទួលបានអាជ្ញាប័ណ្ណទទួលប្រាក់បញ្ញើពីអតិថិជន ។

## ៤. ការប្រឆាំងការសម្អាតប្រាក់

ព្រះរាជាណាចក្រកម្ពុជា បានចូលជាសមាជិករបស់ក្រុមប្រទេសអាស៊ីប៉ាស៊ីហ្វិកស្តីពីការសម្អាតប្រាក់ (APG) នៅខែមិថុនា ឆ្នាំ២០០៤ នៅក្នុងពេលប្រជុំមហាសន្និបាតប្រចាំឆ្នាំលើកទី៧ ដែលបានរៀបចំនៅទីក្រុងសេអ៊ូលនៃសាធារណរដ្ឋកូរ៉េ ។ ក្នុងនាមជាសមាជិកពេញសិទ្ធិ ប្រទេសកម្ពុជាត្រូវអនុវត្តកាតព្វកិច្ចដូចមានចែងនៅក្នុងអនុសញ្ញា ដែលពាក់ព័ន្ធនឹងការសម្អាតប្រាក់និងហិរញ្ញប្បទានភេរវកម្ម អនុសាសន៍ ៤០+៩ ស្តីពីការសម្អាតប្រាក់និងហិរញ្ញប្បទានភេរវកម្មរបស់ក្រុមការងារហិរញ្ញវត្ថុ (FATF) ។

ក្រុមប្រទេសអាស៊ីប៉ាស៊ីហ្វិកស្តីពីការសម្អាតប្រាក់ (APG) បានតម្រូវឱ្យគ្រប់ប្រទេសជាសមាជិកត្រូវមានវិធានការនិងបង្កើតយន្តការក្នុងការរុករក ទប់ស្កាត់ រាល់សកម្មភាពទាំងឡាយ ដែលពាក់ព័ន្ធនឹងការសម្អាតប្រាក់និងហិរញ្ញប្បទានភេរវកម្ម ។ គ្រប់ប្រទេសជាសមាជិកត្រូវបង្កើតឱ្យមានច្បាប់គោលមួយសម្រាប់ប្រឆាំងការសម្អាតប្រាក់និងហិរញ្ញប្បទានភេរវកម្ម ដែលជាវិធានការផ្លូវច្បាប់ដ៏មានប្រសិទ្ធភាព ក្នុងការរុករកនិងទប់ស្កាត់សកម្មភាពទាំងនេះ ហេតុនេះទើបប្រទេស

កម្ពុជា បានដាក់ឱ្យប្រើប្រាស់ជាផ្លូវការនូវច្បាប់ស្តីពីការប្រឆាំងការសម្អាតប្រាក់និងហិរញ្ញប្បទានភេរវកម្ម នៅថ្ងៃទី ២៤ ខែមិថុនា ឆ្នាំ២០០៧ ។

នៅថ្ងៃទី៣០ ខែឧសភា ឆ្នាំ២០០៨ ធនាគារជាតិនៃកម្ពុជា ដែលជាអាជ្ញាធរត្រួតពិនិត្យបុគ្គលរាយការណ៍ជាគ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុ បានចេញផ្សាយប្រកាសស្តីពីប្រឆាំងការសម្អាតប្រាក់និងហិរញ្ញប្បទានភេរវកម្មសម្រាប់គ្រឹះស្ថានទាំងនេះ។ ប្រកាសថ្មីនេះ បានកំណត់ពីវិធានការលម្អិតដែលត្រូវប្រកាន់យកដោយគ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុ រួមមានវិធានការយកចិត្តទុកដាក់ស្គាល់អតិថិជន ការរក្សាទុកឯកសារ ការត្រួតពិនិត្យប្រតិបត្តិការ យន្តការរាយការណ៍ប្រតិបត្តិការសង្ស័យ និងសាច់ប្រាក់ ការបង្កើនការយល់ដឹង និងការត្រួតពិនិត្យផ្ទៃក្នុង ។

នៅថ្ងៃទី២៩ ខែមករា ឆ្នាំ២០០៨ រាជរដ្ឋាភិបាលបានបង្កើតអង្គភាពស៊ើបការណ៍ហិរញ្ញវត្ថុកម្ពុជា ដែលមានតួនាទីចំបងក្នុងការទទួលរបាយការណ៍សង្ស័យ និងព័ត៌មានផ្សេងៗពីបុគ្គលរាយការណ៍ យកមកវិភាគ និងបញ្ជូនទៅអាជ្ញាធរមានសមត្ថកិច្ច ដើម្បីស៊ើបអង្កេត ។ មន្ត្រីត្រួតពិនិត្យកំពុងតែធ្វើការយ៉ាងជិតស្និទ្ធជាមួយនឹងមន្ត្រីស៊ើបការហិរញ្ញវត្ថុ ។

# ឧបសម្ព័ន្ធទី ១

## រចនាសម្ព័ន្ធរបស់នាយកដ្ឋានត្រួតពិនិត្យ



# ឧបសម្ព័ន្ធទី ២

# គ្រឹះស្ថានធនាគារ និងគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ នៅកម្ពុជា

# ឆ្នាំ ២០០៨

(សូមមើលឧបសម្ព័ន្ធទី ២ នៅផ្នែកភាសាអង់គ្លេស)

# ឧបសម្ព័ន្ធទី ៣៖ អត្រាការប្រាក់លើការឱ្យខ្ចីចងការ (ប្រាក់រៀលនិងប្រាក់រូបិយប័ណ្ណ)

ប្រចាំខែធ្នូ ឆ្នាំ២០០៨

អត្រាការប្រាក់ប្រចាំឆ្នាំ

| ល.រ | ឈ្មោះធនាគារ | ឱ្យខ្ចីចងការជាប្រាក់រៀល | | | | | ឱ្យខ្ចីចងការជាប្រាក់ដុល្លារអាមេរិក | | | | | ឱ្យខ្ចីជាប្រាក់រូបិយប័ណ្ណផ្សេងៗ | | | | |
|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|
| | | ថ្ងៃ | ១ខែ | ៣ខែ | ៦ខែ | ១២ខែ | ថ្ងៃ | ១ខែ | ៣ខែ | ៦ខែ | ១២ខែ | ថ្ងៃ | ១ខែ | ៣ខែ | ៦ខែ | ១២ខែ |
| 1 | ធនាគារអេស៊ីលីដាភីអិលស៊ី | | | | | 24.00% | | | | | 18.00% | | | | | 24.00% |
| 2 | ធនាគារវឌ្ឍនៈអាស៊ី ចំកាត់ | | | | | | | 14.00% | 15.00% | 16.00% | 18.00% | | | | | |
| 3 | ធនាគារឯកទេស អានកូ | | | | | | | | | | 15.60% | | | | | |
| 4 | ធនាគារ អេ អិន ហ្សិត រ៉ូយ៉ាល់ កម្ពុជា | | | | | | | | | | 9.92% | | | | | |
| 5 | ធនាគារខ្មែរយូញៀន | | | | | | | 13.00% | 13.00% | 13.00% | 13.00% | | | | | |
| 6 | ធនាគារកម្ពុជាអាស៊ី ចំកាត់ | | | | | | | | | | 18.00% | | | | | |
| 7 | ធនាគារមេគង្គ កម្ពុជា មហាជន ចំកាត់ | | | | | | | 14.40% | 14.40% | 14.40% | 14.40% | | | | | |
| 8 | ធនាគារកម្ពុជាពាណិជ្ជ ចំកាត់ | | | | | | | 15.00% | 15.00% | 15.00% | 15.00% | | 15.00% | 15.00% | 15.00% | 15.00% |
| 9 | ធនាគារឯកទេស ខេមបូឌាន ឌិវេឡុបមេន | | | | | | | 15.00% | 15.00% | 15.00% | 15.00% | | | | | |
| 10 | ធនាគារកម្ពុជាសាធារណៈ ចំកាត់ | | | | | | | 18.00% | 18.00% | 18.00% | 18.00% | | | | | |
| 11 | ធនាគារខេមខូ លីមីតធីត | | | | | | | | | | 13.00% | | | | | |
| 12 | ធនាគារកាណាឌីយ៉ា ក.អ | | 24.00% | 24.00% | 24.00% | 24.00% | | 18.00% | 18.00% | 18.00% | 18.00% | | | | | |
| 13 | ធនាគារពាណិជ្ជទីមួយ សាខាភ្នំពេញ | | | | | | | 15.00% | 15.00% | 15.00% | 15.00% | | | | | |
| 14 | ធនាគារ ឯកទេសវិនិយោគទីមួយ | | | | | | | | 18.00% | 18.00% | 18.00% | | | | | |
| 15 | ធនាគារពាណិជ្ជកម្មក្រៅប្រទេសនៃកម្ពុជា | | 18.00% | 18.00% | 18.00% | 18.00% | | 18.00% | 18.00% | 18.00% | 18.00% | | | | | |
| 16 | ធនាគារក្រុងថៃ ចំកាត់ (មហាជន) | | | | | | | | | | 13.00% | | | | | 10.00% |
| 17 | ធនាគារមេយប៊ែង សាខាភ្នំពេញ | | | | | | | | | | 15.00% | | | | | |
| 18 | ប៉េងហេងអែសអឹមអ៊ី ធនាគារ ចំកាត់ | | | | | | | 24.00% | 24.00% | 24.00% | 24.00% | | | | | |
| 19 | ធនាគារអភិវឌ្ឍន៏ជនបទ | | | | | 15.00% | | | | | 12.00% | | | | | |
| 20 | សាជីវកម្មធនាគារសឹង្ហបូរី ចំកាត់ | | | | | | | | 18.00% | 18.00% | 18.00% | | | | | |
| 21 | ធនាគារសហពាណិជ្ជ ក.អ | | | | | | | | 15.00% | 15.00% | 15.00% | | | | | |
| 22 | ធនាគារវឌ្ឍនៈ | | | | | | | 11.85% | 13.20% | 12.47% | 12.83% | | | | | |
| 23 | ធនាគារវិនិយោគរុងរឿង | | | | | | | | | | 12.00% | | | | | |
| 24 | ធនាគារស៊ិនហានខ្មែរ | | | | | | | 14.00% | 14.00% | 14.00% | 14.00% | | | | | |
| 25 | ម៉ារ៉ូហាន់ធនាគារជប៉ុន | | | | | | | | | | 15.00% | | | | | |
| 26 | ធនាគារ ប៊ូយ៉ុងខ្មែរ | | | | | | | | | | 15.00% | | | | | |
| 27 | ធនាគារភ្នំពេញពាណិជ្ជ | | | | | | | | | | 20.00% | | | | | |
| 28 | ធនាគារឯកទេសបេស | | | | | | | | | | 17.73% | | | | | |
| 29 | ធនាគារ អូ អេស ខេ ឥណ្ឌូឆៃណា | | | | | 18.00% | | | | | 18.00% | | | | | |
| 30 | ធនាគារអង្គរកាពីតាល់ | | | | | | | 24.00% | 24.00% | 24.00% | 24.00% | | | | | |
| | **មធ្យមភាគ** | | **18.77%** | **17.77%** | **18.77%** | **22.36%** | | **16.14%** | **16.29%** | **16.30%** | **15.79%** | | **15.00%** | **15.00%** | **15.00%** | **23.53%** |

## ឧបសម្ព័ន្ធទី៣: អត្រាការប្រាក់លើប្រាក់បញ្ញើ (ប្រាក់រៀលនិងប្រាក់រូបិយប័ណ្ណ)

ប្រចាំខែធ្នូ ឆ្នាំ២០០៨

អត្រាការប្រាក់ប្រចាំឆ្នាំ

| ល.រ | ឈ្មោះធនាគារ | ប្រាក់បញ្ញើជាប្រាក់រៀល | | | | | ប្រាក់បញ្ញើជាប្រាក់ដុល្លារអាមេរិក | | | | | ជាប្រាក់រូបិយប័ណ្ណផ្សេងៗ | | | | |
|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|
| | | សំចៃ | មានកាលកំណត់ | | | | សំចៃ | មានកាលកំណត់ | | | | សំចៃ | មានកាលកំណត់ | | | |
| | | | ១ខែ | ៣ខែ | ៦ខែ | ១២ខែ | | ១ខែ | ៣ខែ | ៦ខែ | ១២ខែ | | ១ខែ | ៣ខែ | ៦ខែ | ១២ខែ |
| 1 | ធនាគារអេស៊ីលីដាភីអិលស៊ី | 4.00% | 5.00% | 6.00% | 8.00% | 9.50% | 2.00% | 4.50% | 5.50% | 6.50% | 7.50% | 4.00% | 5.00% | 6.00% | 7.00% | 8.00% |
| 2 | ធនាគារវឌ្ឍនៈអាស៊ី ចំកាត់ | | 8.20% | 8.25% | | | 1.00% | 4.70% | 5.00% | 6.00% | 8.00% | | | | | |
| 3 | ធនាគារឯកទេស អានកូ | | | | | | | | | | | | | | | |
| 4 | ធនាគារ អេ អិន ហ្ស៊េត រ៉ូយ៉ាល់ កម្ពុជា | 0.50% | 3.55% | 4.60% | 5.55% | 6.70% | 0.25% | 4.55% | 5.45% | 6.05% | 6.35% | 0.87% | 2.75% | 2.86% | 2.83% | 2.81% |
| 5 | ធនាគារខ្មែរយូញៀន | | | | | | 1.00% | 3.00% | 3.00% | 5.00% | 6.00% | | | | | |
| 6 | ធនាគារកម្ពុជាអាស៊ី ចំកាត់ | | | | | | 2.50% | 4.50% | 5.50% | 6.50% | 7.50% | | | | | |
| 7 | ធនាគារមេគង្គ កម្ពុជា មហាជន ចំកាត់ | 3.50% | | | | | 2.00% | 2.25% | 2.75% | 3.25% | 3.50% | 2.00% | | | | |
| 8 | ធនាគារកម្ពុជាពាណិជ្ជ ចំកាត់ | 1.25% | | 1.50% | | | 0.50% | | 3.00% | 3.25% | 3.25% | 0.50% | | 1.00% | | |
| 9 | ធនាគារឯកទេស ខេមបូឌាន ឌិវេឡុបមេន | | | | | | | | | | | | | | | |
| 10 | ធនាគារកម្ពុជាសាធារណៈ ចំកាត់ | 1.00% | | | | | 1.00% | 4.25% | 5.25% | 6.25% | 7.25% | | | | | |
| 11 | ធនាគារខេមខូ លីមីតធីត | | | | | | 1.50% | 3.50% | 4.00% | 5.00% | 6.00% | | | | | |
| 12 | ធនាគារកាណាឌីយ៉ា ក.អ | 2.00% | | 5.00% | 6.00% | 7.00% | 0.75% | 4.00% | 5.00% | 6.00% | 7.00% | | | | | |
| 13 | ធនាគារពាណិជ្ជទីមួយ សាខាភ្នំពេញ | | | | | | 0.40% | 1.25% | 1.35% | 1.45% | 1.55% | | | | | |
| 14 | ធនាគារ ឯកទេសវិនិយោគទីមួយ | | | | | | | | | | | | | | | |
| 15 | ធនាគារពាណិជ្ជកម្មក្រៅប្រទេសនៃកម្ពុជា | 1.50% | | 4.50% | 5.50% | 6.50% | 0.75% | 1.00% | 3.00% | 4.00% | 5.00% | | | | | |
| 16 | ធនាគារក្រុងថៃ ចំកាត់ ( មហាជន) | | | | | | 50.00% | | 1.75% | 2.25% | 2.50% | | | | | |
| 17 | ធនាគារមេយប៊ែង សាខាភ្នំពេញ | | | | | | 0.75% | 1.75% | 2.00% | 2.50% | 3.25% | | | | | |
| 18 | បេងហេងអែសអិមអុ ធនាគារ ចំកាត់ | | | | | | | | | | | | | | | |
| 19 | ធនាគារអភិវឌ្ឍន៍ជនបទ | 1.50% | 3.50% | 4.00% | 5.00% | 6.00% | 1.00% | 3.00% | 3.50% | 4.00% | 5.00% | | | | | |
| 20 | សាជីវកម្មធនាគារសិង្ហបូរី ចំកាត់ | | | | | | 0.50% | | 3.00% | 3.50% | 4.50% | | | | | |
| 21 | ធនាគារសហពាណិជ្ជ ក.អ | | | | | | 2.00% | | 4.50% | 5.50% | 7.50% | | | | | |
| 22 | ធនាគារវឌ្ឍនៈ | | | | | | 1.00% | 3.50% | 4.25% | 5.25% | 6.00% | | | | | |
| 23 | ធនាគារវិនិយោគរុងរឿង | 2.00% | 3.55% | 4.60% | 5.55% | 6.50% | 2.00% | 3.00% | 4.00% | 4.75% | 6.00% | | | | | |
| 24 | ធនាគារស៊ីនហានខ្មែរ | | | | | | 1.00% | 4.05% | 4.15% | 5.00% | 6.00% | | | | | |
| 25 | មារូហាន់ធនាគារជប៉ុន | 1.50% | 3.00% | 4.00% | 5.00% | 6.25% | 1.50% | 3.75% | 4.00% | 5.00% | 5.25% | | | | | |
| 26 | ធនាគារ ប៊ូយ៉ុងខ្មែរ | 1.00% | | | | | 1.00% | 3.00% | 4.00% | 5.00% | 6.00% | | | | | |
| 27 | ធនាគារភ្នំពេញពាណិជ្ជ | | | | | | 1.20% | 3.70% | 4.20% | 5.20% | 6.20% | | | | | |
| 28 | ធនាគារឯកទេសបេស | | | | | | | | | | | | | | | |
| 29 | ធនាគារ អូ អេស ខេ ឥណ្ឌូឆៃណា | 1.50% | 3.50% | 4.00% | 5.00% | 6.00% | 1.25% | 3.50% | 4.25% | 5.25% | 6.00% | | | | | |
| 30 | ធនាគារអង្គរកាពីតាល់ | | | | | | 2.00% | 5.00% | 5.00% | 6.50% | 7.50% | | | | | |
| **WEIGHTED AVERAGE** | | **2.05%** | **4.48%** | **5.20%** | **6.46%** | **7.65%** | **1.08%** | **3.75%** | **4.60%** | **5.48%** | **6.34%** | **2.55%** | **4.02%** | **4.63%** | **5.18%** | **5.73%** |

## ឧបសម្ព័ន្ធទី ៤: ប្រព័ន្ធធនាគារកម្ពុជា

ថ្ងៃទី ៣១ ខែធ្នូ ឆ្នាំ ២០០៨

### ធនាគារជាតិ នៃកម្ពុជា

**២៤ ធនាគារពាណិជ្ជ**

- ៣ សាខាធនាគារបរទេស
  - ធនាគារ ពាណិជ្ជកម្មទីមួយ
  - ធនាគារ ក្រុងថៃ
  - ធនាគារ មេយបែង
- ២១ បង្កើតឡើងតាមច្បាប់ក្នុងស្រុក
  - ធនាគារពាណិជ្ជកម្មក្រៅប្រទេស
  - ធនាគារ វឌ្ឍនៈអាស៊ី
  - ធនាគារ កម្ពុជាអាស៊ី
  - ធនាគារ កាណាឌីយ៉ា
  - ធនាគារ កម្ពុជាពាណិជ្ជ
  - ធនាគារ កម្ពុជាមេគង្គ
  - ធនាគារ កម្ពុជាសាធារណៈ
  - សាជីវកម្ម ធនាគារ សិង្ហបុរី
  - ធនាគារ សហពាណិជ្ជ
  - ធនាគារ វឌ្ឍនៈ
  - ធនាគារ អេស៊ីលីដា
  - ធនាគារ អេអ៊ិនហ្សេតរ៉ូយ៉ាល់
  - ធនាគារខេមខូ
  - ធនាគារ ស៊ិនហាន ខ្មែរ
  - ធនាគារវិនិយោគរុងរឿង
  - ម៉ារ៉ូហាន់ ធនាគារ ជប៉ុន
  - ធនាគារខ្មែរយូញៀន
  - ធនាគារប៊ូយុងខ្មែរ
  - ធនាគារភ្នំពេញពាណិជ្ជ
  - ធនាគារ អូ អេស ខេ ឥណ្ឌូឆៃណា
  - ធនាគារ អង្គរកាពីតាល់

**៦ ធនាគារឯកទេស**

- ១ ធនាគាររដ្ឋ
  - ធនាគារ អភិវឌ្ឍន៍ជនបទ
- ៥ ធនាគារឯកជន
  - ធនាគារ ប៉េងហេង S.M.E.
  - ធនាគារឯកទេសវិនិយោគទីមួយ
  - ធនាគារ ឯកទេសអានកូ
  - ធនាគារ ឯកទេសខេមបូឌាន ឌីវឡុបមេន
  - ធនាគារឯកទេស ប៊េស

**• ២ ការិយាល័យតំណាង**

- ស្តង់ដារឆាទីរ៉ែត
- ធនាគារកសិកម្មនិងអភិវឌ្ឍន៍នៃវៀតណាម

**គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ**

- • ១៨ មានអាជ្ញាប័ណ្ណ
  - 1- អម្រឹត
  - 2-ហត្ថាកសិករ
  - 3-តុងហ្វុងមីក្រូហិរញ្ញវត្ថុ
  - 4-ធនាគារភូមិកម្ពុជា
  - 5-សិលានិធិ
  - 6-ក្រុមហ៊ុនស្ថាបនាសហគ្រិនកម្ពុជា
  - 7-ក្រុមហ៊ុនអង្គរមីក្រូហិរញ្ញវត្ថុ
  - 8-វីសុនហ្វាន់(ខេមបូឌា)
  - 9-ក្រុមហ៊ុនក្រេឌីត Co.Ltd.
  - 10-ប្រាសាក់ ម៉ាយក្រូហ្វាយនែន
  - 11-សមាគមមូលនិធិសហភាពអភិ.កសិករ
  - 12-ក្រុមហ៊ុនអភិវឌ្ឍន៍សេដ្ឋកិច្ចជនបទកម្ពុជា
  - 13-ម៉ាក់ស៊ីម៉ា មីក្រូហិរញ្ញវត្ថុ
  - 14-ឥណទានពលរដ្ឋរុងរឿង
  - 15- ស៊ីអេជស៊ី លីមីធីត
  - 16- ហ្វាមើរ ហ្វាយនែន
  - 17. ឥណទានអភិវឌ្ឍន៍ប្រជាជន
  - 18- ហ្រ្វិន សេនត្រស ម៉ាយក្រូហ្វាយនែន
- អង្គការក្រៅរដ្ឋាភិបាល
  - • ២៦ ចុះបញ្ជី *
  - • មិនចុះបញ្ជីមានប្រហែល៦០ទៀត

**២១សាខាធនាគារជាតិនៅតាមខេត្ត**

- ក្រុងភ្នំពេញ
- កំពង់ចាម
- ក្រុងព្រះសីហនុ
- សៀមរាប
- បាត់ដំបង
- ស្វាយរៀង
- កំពត
- កណ្តាល
- កំពង់ធំ
- ពោធិសាត់
- កំពង់ស្ពឺ
- កោះកុង
- រតនៈគិរី
- មណ្ឌលគិរី
- ព្រៃវែង
- តាកែវ
- កំពង់ឆ្នាំង
- ព្រះវិហារ
- ក្រចេះ
- ស្ទឹងត្រែង
- បន្ទាយមានជ័យ

**អាជីវកម្មប្តូរប្រាក់**

- • ចុះបញ្ជីខេត្ត/ក្រុង 4.320

• បើកជាផ្លូវការ

* អង្គការក្រៅរដ្ឋាភិបាលដែលបានចុះបញ្ជីចំនួន ២៦

| | |
|---|---|
| ១-សមាគមអភិវឌ្ឍន៏កសិករនិងទេសចរ | ១៤-អង្គការឥស្លាមអភិវឌ្ឍន៏ជនបទ |
| ២-សមាគមជួយកសិករ | ១៥- អង្គការអភិវឌ្ឍន៏ជនបទខ្មែរ |
| ៣-សមាគមផ្តើមគំនិតពាណិជ្ជកម្ម | ១៦- សមាគមសុខុមាលស្ត្រីខេត្តក្រចេះ |
| ៤-អង្គការអភិវឌ្ឍន៏សព្វការជាតិខ្មែរ | ១៧- អង្គការលូថេរ៉ានបំរើពិភពលោក |
| ៥-សមាគមសំណាងអភិវឌ្ឍន៏ជនបទ | ១៨- គំរោងឥណទានក្រសួងអភិវឌ្ឍន៏ជនបទ |
| ៦-សមាគមអភិវឌ្ឍន៏ពុទ្ធសាសនានិងទ្រទ្រង់បរិស្ថាន | ១៩- សមាគមអភិវឌ្ឍន៏តំបន់ពាយ័ព្យ |
| ៧-សហព័ន្ធសហគមសន្សំប្រាក់កម្ពុជា | ២០- សមាគមអភិវឌ្ឍន៏ស្រុកស្រែ |
| ៨-ឥណទានលុបបំបាត់ភាពក្រីក្រ | ២១- អភិវឌ្ឍន៏សេដ្ឋកិច្ចជនបទ |
| ៩-អង្គការសង្គហអភិវឌ្ឍន៏កម្ពុជា | ២២- អង្គការអភិវឌ្ឍន៏គ្រួសារជនបទ |
| ១០-អភិវឌ្ឍន៏សេដ្ឋកិច្ចជនបទនៅកម្ពុជា | ២៣- អង្គការអភិវឌ្ឍន៏សង្គមជនបទ |
| ១១-អង្គការអភិវឌ្ឍន៏ស្ត្រីកម្ពុជា | ២៤- សមាគមអភិវឌ្ឍន៏សណ្តែកសៀងតាអុង |
| ១២-ស៊ីអាយស៊ីអេម កម្ពុជា | ២៥- កម្មវិធីអភិវឌ្ឍន៏ស្ត្រីក្នុងសហគមនៃខ័ណ្ឌមានជ័យ |
| ១៣-សមាគមជាតិទ្រទ្រង់កសិផល | ២៦- អង្គការបណ្តាញសេដ្ឋកិច្ចកម្ពុជា |